**នៅចំពោះមុខអង្គជំនុំជម្រះតុលាការកំពូល**
**នៃអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា**

ឯកសារដើម
ORIGINAL/ORIGINAL
ថ្ងៃ ខែ ឆ្នាំ (Date): 25-Mar-2011, 11:17
CMS/CFO: Uch Arun

**ព័ត៌មានពិស្តារនៃការដាក់ឯកសារ**

| | | |
|---|---|---|
| សំណុំរឿងលេខ | : | ០០១/១៨-០៧-២០០៧-អវតក/អជតក |
| ដាក់ទៅ | : | អង្គជំនុំជម្រះតុលាការកំពូល |
| ថ្ងៃដាក់ | : | ថ្ងៃទី២៥ ខែមីនា ឆ្នាំ២០១១ |
| ភាគីអ្នកដាក់ | : | សហព្រះរាជអាជ្ញា |
| ភាសាដើម | : | ខ្មែរ |

**ចំណាត់ថ្នាក់ឯកសារ**

ប្រភេទឯកសារដែលស្នើឡើងដោយភាគីដាក់ឯកសារ: សាធារណៈ

ចំណាត់ថ្នាក់ឯកសារកំណត់ដោយអង្គជំនុំជម្រះ: សាធារណៈ/Public

ប្រភេទនៃចំណាត់ថ្នាក់ឯកសារ:

ការពិនិត្យចំណាត់ថ្នាក់ឯកសារបណ្ដោះអាសន្នឡើងវិញ:

ឈ្មោះមន្ត្រីដែលបានពិនិត្យ:

ហត្ថលេខា:

---

**ចម្លើយតបរបស់សហព្រះរាជអាជ្ញា ទៅនឹងពាក្យសុំបន្ថែមភស្តុតាងថ្មី និងឧបសម្ពន្ធ "ក" របស់សហមេធាវីការពារក្តី កាំង ហ្កេកអ៊ាវ *ហៅ* "ឌុច" ប្រឆាំងនឹងសាលក្រម របស់អង្គជំនុំជម្រះសាលាដំបូង**

---

| **អ្នកដាក់ឯកសារ:** | **អ្នកទទួលឯកសារ:** | **ចម្លងជូន:** |
|---|---|---|
| **សហព្រះរាជអាជ្ញា:** | **អង្គជំនុំជម្រះតុលាការកំពូល:** | **មេធាវីដើមបណ្តឹងរដ្ឋប្បវេណី:** |
| លោកស្រី ជា លាង | ចៅក្រម គង់ ស្រ៊ីម, ប្រធាន | លោក គង់ ពិសី |
| លោក Andrew CAYLEY | ចៅក្រម Motoo NOGUCHI | លោក ហុង គឹមសួន |
| | ចៅក្រម សោម សិរីវឌ្ឍ | លោក យុង ផានិត |
| | ចៅក្រម A. KLONOWIECKA-MILART | លោក គីម ម៉េងឃី |
| | ចៅក្រម ស៊ិន វិទ្ធ | កញ្ញា ម៉ុច សុវណ្ណារី |
| | ចៅក្រម C. N. JAYASINGHE | កញ្ញា SILKE Studzinsky |
| | ចៅក្រម យ៉ា ណារិន | លោកស្រី Martine JACQUIN |

០០១/១៨-០៧-២០០៧-អវតក/អជតក

**មេធាវីជនជាប់ចោទ:**
**កាំង ហ្គេកអ៊ាវ *ហៅ* ឌុច:**

លោក ការ សាវុត្ថ
លោក កង ឫទ្ធារី

លោក Philippe CANONNE
លោកស្រី ទី ស្រ៊ីនណា
លោក Pierre-Olivier SUR
លោក Alain WERNER
លោក Brianne McGONIGLE
លោកស្រី Annie DELAHAIE
លោកស្រី Elizabeth RABESANDRATANA
លោក Karim KHAN
លោកស្រី Fabienne TRUSSES-NAPROUS

*០០១/១៨-០៧-២០០៧-អវតក/អជតក*

# I. សេចក្តីផ្តើម

១- នៅថ្ងៃទី១៨ វិច្ឆិកា ឆ្នាំ២០១០ សហមេធាវីការពារក្តី កាំង ហ្កេកអ៊ាវ *ហៅ* "ឌុច" ("ជនជាប់ចោទ") បានដាក់សារណាបណ្តឹងសាទុក្ខ ប្រឆាំងនឹងសាលក្រមរបស់អង្គជំនុំជម្រះសាលាដំបូង ចុះថ្ងៃទី២៦ ខែកក្កដា ឆ្នាំ២០១០ ("បណ្តឹងសាទុក្ខ")[1] ព្រមជាមួយឧបសម្ពន្ធ "ក"[2]។ សហព្រះរាជអាជ្ញាបានដាក់ចម្លើយតបរបស់ខ្លួនទៅនឹងបណ្តឹងសាទុក្ខនេះ នៅថ្ងៃទី២០ ខែធ្នូ ឆ្នាំ២០១០ ("ចម្លើយតបរបស់ការិយាល័យសហព្រះរាជអាជ្ញា")[3]។ នៅថ្ងៃទី១១ ខែមករា ឆ្នាំ២០១១ សហមេធាវីការពារក្តី កាំង ហ្កេកអ៊ាវ *ហៅ* "ឌុច" ("សហមេធាវីការពារក្តី") បានដាក់ចម្លើយតបរបស់ខ្លួនទៅនឹងចម្លើយតបរបស់សហព្រះរាជអាជ្ញា ("ចម្លើយតបរបស់សហមេធាវីការពារក្តី")[4]។

២- នៅថ្ងៃទី២១ ខែកុម្ភៈ ឆ្នាំ២០១១ អង្គជំនុំជម្រះតុលាការកំពូលបានបង្គាប់ឲ្យសហមេធាវីការពារក្តីដាក់ភស្តុតាងបន្ថែមតាមខ្លឹមសារនៃអនុស្សរណៈរបស់អង្គជំនុំជម្រះតុលាការកំពូល("អនុស្សរណៈ")[5]។

---

[1] សារណារបស់សហមេធាវីការពារក្តីជនជាប់ចោទ កាំង ហ្កេកអ៊ាវ *ហៅ* "ឌុច" អំពីបណ្តឹងសាទុក្ខប្រឆាំងនឹងសាលក្រម ចុះថ្ងៃទី២៦ ខែកក្កដា ឆ្នាំ២០១០ របស់អង្គជំនុំជម្រះសាលាដំបូង, សំណុំរឿងលេខ: ០០១/១៨-០៧-២០០៧-អវតក/អជតក, មេធាវីការពារក្តី, ១៨ វិច្ឆិកា ២០១០, F14 ("បណ្តឹងសាទុក្ខ")។

[2] សារណារបស់សហមេធាវីការពារក្តីជនជាប់ចោទ កាំង ហ្កេកអ៊ាវ *ហៅ* "ឌុច" អំពីបណ្តឹងសាទុក្ខប្រឆាំងនឹងសាលក្រម ចុះថ្ងៃទី២៦ ខែកក្កដា ឆ្នាំ២០១០ របស់អង្គជំនុំជម្រះសាលាដំបូង, សំណុំរឿងលេខ: ០០១/១៨-០៧-២០០៧-អវតក/អជតក, មេធាវីការពារក្តី, ១៨ វិច្ឆិកា ២០១០, F14.2 (បណ្តឹងសាទុក្ខឧបសម្ពន្ធ "ក")។

[3] ចម្លើយតបរបស់សហព្រះរាជអាជ្ញា ទៅនឹងបណ្តឹងសាទុក្ខរបស់មេធាវីការពារក្តីរបស់ កាំង ហ្កេកអ៊ាវ ហៅ "ឌុច" ប្រឆាំងនឹងសាលក្រមរបស់អង្គជម្រះសាលាដំបូង ចុះថ្ងៃទី២៦ ខែកក្កដា ឆ្នាំ២០១០, សំណុំរឿងលេខ: ០០១/១៨-០៧-២០០៧-អវតក/អជតក, ការិយាល័យសហព្រះរាជអាជ្ញា, ២០ ធ្នូ ២០១០, F14/4 ("ចម្លើយតបរបស់ការិយាល័យសហព្រះរាជអាជ្ញា")។

[4] ចម្លើយតបរបស់សហមេធាវីការពារក្តីជនជាប់ចោទ កាំង ហ្កេកអ៊ាវ *ហៅ* "ឌុច" ទៅនឹងចម្លើយតបរបស់សហព្រះរាជអាជ្ញា ចុះថ្ងៃ២០ ខែធ្នូ ឆ្នាំ២០១០, សំណុំរឿងលេខ: ០០១/១៨-០៧-២០០៧-អវតក/អជតក, មេធាវីការពារក្តី, ១៤ មករា ២០១១, F14/4/2 ("ចម្លើយតបរបស់មេធាវីការពារក្តី")។

[5] អនុស្សរណៈ របស់អង្គជំនុំជម្រះតុលាការកំពូល, សំណុំរឿងលេខ: ០០១/១៨-០៧-២០០៧-អវតក/អជតក, ចុះថ្ងៃទី២១ ខែកុម្ភៈ ឆ្នាំ២០១១ F17 ("អនុស្សរណៈ")។

៣- នៅថ្ងៃទី២៥ ខែកុម្ភៈ ឆ្នាំ២០១១ សហមេធាវីការពារក្តី បានដាក់ពាក្យស្នើសុំបន្ថែមភស្តុតាងថ្មី ("ពាក្យស្នើសុំបន្ថែមភស្តុតាងថ្មី")[6]។ សំណើនេះមិនគោរពទៅតាមវិធាន ១០៨(៧)។

## II. **សារតារនាក់ខចនឹចតស្តុតាចថ្មី**

៤- នៅពេលសហមេធាវីការពារក្តី ដាក់សារណារបស់ខ្លួន អំពីបណ្តឹងសាទុក្ខប្រឆាំងនឹងសាលក្រម របស់អង្គជំនុំជម្រះសាលាដំបូង ចុះថ្ងៃទី២៦ ខែកក្កដា ឆ្នាំ២០១០ សហមេធាវីការពារក្តី បាន ដាក់ភ្ជាប់នឹងឧបសម្ព័ន្ធ"**ក**" ដែលនៅក្នុងនោះមានឯកសារភស្តុតាងថ្មីបន្ថែមចំនួន៥ ដូចខាងក្រោម៖

ក. មជ្ឈមណ្ឌលឯកសារកម្ពុជា (គុកខ្មែរក្រហម) ទំព័រ ៨១ ចងក្រងដោយ **ផេង ពង្សរ៉ាស៊ី** (ភាសាខ្មែរដើម)/អង់គ្លេស "បកប្រែ" (F14.2.1)។

ខ. ឯកសារស្វែងរកការពិតរបស់មជ្ឈមណ្ឌលឯកសារកម្ពុជាលេខ២ ខែ កុម្ភៈ ឆ្នាំ ២០០០ ទំព័រ៥៣ (ភាសាខ្មែរ/អង់គ្លេស) (F14.2.2)។

គ. ប្រជុំរឿងព្រេងខ្មែរ ភាគ៣ បោះពុម្ព ឆ្នាំ២០០១ ទំព័រ១៣៧-១៤៤ (ភាសាខ្មែរ "ដើម"/ ភាសាអង់គ្លេស "បកប្រែ") (F14.2.3)។

ឃ. សេចក្តីសន្និដ្ឋានរបស់ DC-Cam ដាក់ជូនគណៈកម្មាធិការជំនាញរបស់ UN ជីវប្រវត្តិ របស់ ឌុច (ភាសាអង់គ្លេស "ដើម" / ភាសាខ្មែរ "បកប្រែ") (F14.2.4)។

ង. រចនាសម្ព័ន្ធគ្រប់គ្រងបញ្ជាលើ ស-២១ "គុកសម្ងាត់ឃោឌា" ហៅ គុកទួលស្លែង របស់ រដ្ឋាភិបាលកម្ពុជាប្រជាធិបតេយ្យ ពីខែមីនា ឆ្នាំ១៩៧៦ ដល់ថ្ងៃទី១៥ ខែសីហា ឆ្នាំ១៩៧៧ និងពីថ្ងៃទី១៥ ខែសីហា ឆ្នាំ១៩៧៧ ដល់ថ្ងៃទី០៦ ខែមករា ឆ្នាំ១៩៧៩ (ភាសាខ្មែរ/ភាសា អង់គ្លេស) (F14.2.5)។

---

[6] ពាក្យស្នើសុំបន្ថែមភស្តុតាងថ្មីរបស់មេធាវីការពារក្តី ជនជាប់ចោទ កាំង ហ្កេកអ៊ាវ *ហៅ* "ឌុច" , សំណុំរឿងលេខ: ០០១/១៨-០៧-២០០៧-អវតក/អជតក, ចុះថ្ងៃទី២៥ ខែកុម្ភៈ ឆ្នាំ២០១១ F2/2 ("ពាក្យស្នើសុំបន្ថែមភស្តុតាងថ្មី")។

៥- នៅពេលសហមេធាវីការពារក្តីដាក់ពាក្យសុំបន្ថែមភស្តុតាងថ្មី សហមេធាវីការពារក្តីបានស្នើសុំដាក់៖

ក. "គុកខ្មែរក្រហម" ឯកសាររបស់មជ្ឈមណ្ឌលឯកសារកម្ពុជា (DC-Cam) ដែលចងក្រងដោយលោក **ផេង ពង្សរ៉ាស៊ី** មានចំនួន ៣២៨ទំព័រ ជាភាសាខ្មែរ ដែលភ្ជាប់ដោយលិខិតបញ្ជាក់ការជំនួសឯកសារ[7]។

ខ. សេចក្តីសន្និដ្ឋានរបស់ DC-Cam ដែលដាក់ជូនគណៈកម្មាធិការជំនាញរបស់ UN ដែលមានចំណងជើងថា "The Selected 31 Biographies of Khmer Rouge Leaders and Others, prepared for the UN Commission of Experts August-September, 1998"។

៦- ចំពោះឯកសារស្តីពី មជ្ឈមណ្ឌលឯកសារកម្ពុជា (គុកខ្មែរក្រហម) ទំព័រ ៨១ ចងក្រងដោយ **ផេង ពង្សរ៉ាស៊ី** (ភាសាខ្មែរ"ដើម")/អង់គ្លេស"បកប្រែ" ម្តង សហមេធាវីការពារក្តីបានលើកយោងតែមួយទំព័រប៉ុណ្ណោះ នៅក្នុងសារណាបណ្តឹងសាទុក្ខភ្ជាប់ឧបសម្ព័ន្ធ "**ក**" ហើយក្រោយមកទៀត សហមេធាវីការពារក្តីបានលើកយោងសៀវភៅទាំងស្រុងតែម្តង នៅក្នុងពាក្យសុំបន្ថែមភស្តុតាងថ្មី។ ខ្លឹមសារនៃឯកសារទំព័រ៨១នេះ មាននៅក្នុងសំណុំរឿងរួចហើយ[8]។

៧- ចំពោះឯកសារស្តីពី រចនាសម្ពន្ធគ្រប់គ្រងបញ្ជាលើ ស-២១ "គុកសម្ងាត់យោធា" ហៅ គុកទួលស្លែង របស់រដ្ឋាភិបាលកម្ពុជាប្រជាធិបតេយ្យ ពីខែមីនា ឆ្នាំ១៩៧៦ ដល់ថ្ងៃទី១៥ ខែសីហា ឆ្នាំ១៩៧៧ និងពីថ្ងៃទី១៥ ខែសីហា ឆ្នាំ១៩៧៧ ដល់ថ្ងៃទី០៦ ខែមករា ឆ្នាំ១៩៧៩ ជាឯកសារដែលសហមេធាវីការពារក្តីបានស្រាវជ្រាវ ហើយ**ចងក្រងដោយសហមេធាវីការពារក្តី**។ ដូច្នេះ ឯកសារនេះមិនអាចបង្កើតបានជាភស្តុតាងដែលអាចទទួលស្គាល់បានទេ។

---

[7] លិខិតបញ្ជាក់ការជំនួសឯកសារ F2/2.1

[8] ឯកសារ D២០៤/៣.១ នៅទំព័រ ERN00៣៧៩១00 និងឯកសារ D២០៤/៣.២ នៅទំព័រ ERN00៣៩៧៩0៨។

៨- ចំពោះឯកសារស្វែងរកការពិតរបស់មជ្ឈមណ្ឌលឯកសារកម្ពុជាលេខ២ ខែកុម្ភៈ ឆ្នាំ២000 ទំព័រ ៥៣ និងឯកសារស្តីពីសេចក្តីសន្និដ្ឋានរបស់ DC-Cam ដាក់ជូនគណៈកម្មាធិការជំនាញរបស់ UN គឺជាឯកសារពាក់ព័ន្ធអំពីជីវប្រវត្តិរបស់ ឌុច។ ខ្លឹមសារទូទៅរបស់ឯកសារនេះ មាននៅក្នុងកំណត់ហេតុយកចំលើយរបស់ ឌុច ជាច្រើនដែលក្នុងនោះ ឌុច បានបញ្ជាក់ថា ខ្លួនជាប្រធានមន្ទីរសន្តិសុខ ស-២១ ហើយ ឌុច ទទួលបញ្ជាផ្ទាល់ពី សុន សេន និងក្រោយមក នួន ជា[9]។

៩- ចំពោះឯកសារប្រជុំរឿងព្រេងខ្មែរ ភាគ៣ បោះពុម្ព ឆ្នាំ២០០១ ទំព័រ១៣៧-១៤៤ ទាំងខ្លឹមសារ និងឯកសារនេះ មិនដែលធ្លាប់មាននៅក្នុងសំណុំរឿងទេ។ ជាងនេះទៀត ខ្លឹមសារនៃឯកសារនេះ មិនពាក់ព័ន្ធនឹងអង្គហេតុ នៃឧក្រិដ្ឋកម្មដែលបានកើតឡើងនៅក្នុងរបបកម្ពុជាប្រជាធិបតេយ្យ ដែលឋិតនៅក្រោមយុត្តាធិការរបស់ អវតក ទេ។

## III. សំណើ

១០- មូលហេតុដូចដែលបានរៀបរាប់ខាងលើ សហព្រះរាជអាជ្ញាស្នើសុំអង្គជំនុំជម្រះតុលាការកំពូល បដិសេធចោលនូវឯកសារភស្តុតាងបន្ថែមថ្មីទាំងអស់ ដែលបានស្នើឡើងដោយសហមេធាវីការពារក្តី កាំង ហ្គេកអ៊ាវ *ហៅ* “ឌុច”។

| កាលបរិច្ឆេទ | ឈ្មោះ | ទីកន្លែង | ហត្ថលេខា |
|---|---|---|---|
| ថ្ងៃទី២៥ ខែមីនា ឆ្នាំ២០១១ | **លោកស្រី ជា លាង**<br>សហព្រះរាជអាជ្ញា | ភ្នំពេញ | [signature] |
| | **លោក** Andrew CAYLEY<br>សហព្រះរាជអាជ្ញា | | [signature] |

[9] កំណត់ហេតុយកចម្លើយ ឌុច នៅចំពោះមុខសហចៅក្រមស៊ើបអង្កេត កាលពីថ្ងៃទី១៥ ខែកុម្ភៈ ឆ្នាំ២០០៨, D៤៧, ERN00១៦៤៣៤៥ ត្រង់ទំព័រទី៣, កំណត់ហេតុយកចម្លើយ ឌុច នៅចំពោះមុខសហចៅក្រមស៊ើបអង្កេត កាលពីថ្ងៃទី៧ ខែសីហា ឆ្នាំ២០០៧, D១១, ERN 00១៤៧៥១៧, ទំព័រ៣ ។